# សក្រវាទី ឱណា ផ្កាក្រវាន់



សក្រវាទ៏ ឱណា ឱផ្កាក្រវាន់
បើអូនប្រកាន់ រៀមបងប្រកែក
សក្រវាទ៏ ឱណា ឱផ្កាត្របែក
បើអូនប្រកែក រៀមបងប្រកាន់។
មែនហើយ ឱណាមែនហើយ
បើអូនប្រកែក រៀមបងប្រកាន់។





សក្រវាទ៏ ឱណា ឱផ្កាកញ្ចែត
មិនទាន់ញាំឆ្អែត ក្រពះវាទារ
សក្រវាទ៏ ឱណា ឱផ្កាពុទ្រា
ក្រពះវាទារ ត្រូវញ៉ាំឱ្យឆ្អែត។
មែនហើយ ឱណាមែនហើយ
ក្រពះវាទារ ត្រូវញ៉ាំឱ្យឆ្អែត។





បើនាងបុកស្រូវ កុំចោលកន្ទក់
ចិញ្ចឹមជ្រូកលក់ បានប្ញូនដប់ម្ភៃ
ក្រែងលោឆ្នាំក្រោយរៀបការអូនស្រី
មិនព្រួយមិនភ័យនឹងរកទិញគេ។
មែនហើយ ឱណាមែនហើយ
មិនព្រួយមិនភ័យនឹងរកទិញគេ។









កង្កែបវាយំ ក្រមុំវាផ្អើល
រត់មិនបានមើល ទៅជាន់ចានជ្រក់
កណ្តាបបុកស្រូវគេឱ្យថ្នាំជក់
កណ្តាបដេកលក់ គេជក់ថ្នាំអស់។
មែនហើយ ឱណាមែនហើយ
កណ្តាបដេកលក់គេជក់ថ្នាំអស់។





កន្ទ្រេត ទ្រែតអើយ ដើរកាត់កន្ទ្រើយ
កន្ទ្រេតលាត់សើយ បញ្ចេញគល់ភ្លៅ
ពេលអូនឃើញបង មុខឡើងក្រញូវ
ខ្មាសអីស្រីពៅ ភ្លៅដូចតែគ្នា។
មែនហើយ ឱណាមែនហើយ
ខ្មាសអីស្រីពៅ ភ្លៅដូចតែគ្នា។





ផ្គរលាន់ឯត្បូង ត្រយូងចេកជ្វា
ចាស់ៗឈ្លោះគ្នា ព្រោះរើសកូនប្រសា
ឪត្រូវអ្នកស្រែ ម៉ែត្រូវអ្នកផ្សារ
សម្រេចសាច់ការ ប៉ះលើអាចារ្យស្រិប។
មែនហើយ ឱណាមែនហើយ
សម្រេចសាច់ការ ប៉ះលើអាចារ្យស្រិប។



សិល្បករៈ ស៊ិន ស៊ីសាមុត

អាចារ្យស្រិប = ពាក្យគ្រលាស់ អាជិបស្រោ = អ្នកប្រមឹក